
www.kidsofdestiny.org
Kids of Destiny®

## 1.02 ការធ្លាក់ចុះ

**លោកុប្បត្តិ ៣: ១-២៤**

នៅពេលដែលព្រះទ្រង់បានបង្កើតផ្ទៃមេឃនិងផែនដី អ្វីៗគឺល្អឥតខ្ចោះ ។ ព្រះទ្រង់បានបង្កើតមនុស្សដំបូងគឺ អ័ដាម និងអេវ៉ា នៅក្នុងទំនាក់ទំនងដ៏ល្អឥតខ្ចោះជាមួយព្រះ។ ប៉ុន្តែនោះមិនបានជារៀងរហូតទេ ។ តើមានអ្វីកើតឡើង? នៅពេលដែលព្រះទ្រង់បានបង្កើតពិភពលោកហើយ ទ្រង់បានដាក់ច្បាប់តែមួយប៉ុណ្ណោះ "ឯងមិនត្រូវបរិភោគផ្លែឈើពីដើមដឹងខុសត្រូវ ល្អ និងអាក្រក់ទេ ។ បើឯងស៊ីវា សេចក្តីស្លាប់ និងសេចក្តីទុក្ខព្រួយនឹងមកដល់ ។

ប៉ុន្តែ សាតាំងដែលជាខ្មាំងសត្រូវរបស់ព្រះអម្ចាស់ វាមិនចូលចិត្តការបង្កើតថ្មីរបស់ព្រះអង្គទេ ។ បេសកម្មរបស់វា គឺ សម្លាប់ លួច និងបំផ្លាញ នូវអ្វីៗទាំងអស់ដែលព្រះទ្រង់បានបង្កើតមក។ សាតាំងបានបង្កើតផែនការអាក្រក់មួយ ។ វាបានចូលក្នុងសួនច្បារ ហើយក្លាយខ្លួនជាពស់ វាបាននិយាយកុហកអេវ៉ា ហើយបោកបញ្ឆោតអេវ៉ាឱ្យបរិភោគផ្លែឈើពីដើមដឹងខុសត្រូវ ល្អ និងអាក្រក់។ ជាអកុសល អេវ៉ាសម្រេចចិត្តស្តាប់តាមពស់ ហើយនាងមិនគោរពតាមច្បាប់របស់ព្រះទេ។ ហើយមិនត្រឹមតែនាងបានញ៉ាំប៉ុណ្ណោះទេប៉ុន្តែនាងថែមទាំងបានឲ្យផ្លែឈើនោះដល់អ័ដាមទៀត ហើយគាត់ក៏បានបរិភោគវាដែរ ។

ដោយសារតែការញ៉ាំផ្លែឈើមួយម៉ាត់នោះអ័ដាមនិងអេវ៉ាបានផ្តាច់ទំនាក់ទំនងដ៏ល្អឥតខ្ចោះរបស់ពួកគេជាមួយព្រះអម្ចាស់។ ពួកគេបានដឹងខ្លួនយឺតពេលទៅហើយ ដែលពួកគេបានធ្វើការជ្រើសរើសខុសដោយមិនគោរពតាមព្រះអម្ចាស់ នេះហៅថាជាអំពើរបាប។ អំពើរបាបដូចជាក្លិនមួយដែលចេញមកពីសពសត្វដែលបានស្លាប់រួចហើយ លទ្ធផលគឺសេចក្តីស្លាប់។អំពើបាបមិនត្រឹមតែនាំមកនូវសេចក្តីស្លាប់ខាងរូបកាយប៉ុណ្ណោះទេប៉ុន្តែវាក៏រារាំងយើងមិនឲ្យនៅជាប់ជាមួយព្រះដែរ។ ពួកយើងត្រូវកាត់ចេញពីស្ថានសួគ៌ជារៀងរហូត។ ប្រៀបដូចជាអ័ដាមនិងអេវ៉ាអញ្ចឹង គឺពួកគេត្រូវចាកចេញពីផ្ទះដ៏ល្អឥតខ្ចោះរបស់ពួកគេជារៀងរហូត។ នេះគឺជាការចាប់ផ្តើមនៃការខ្មាស់អៀន ដឹងខ្លួនខុសនិងការភ័យខ្លាច។ នេះគឺជាពេលដែលភាពអស់សង្ឃឹម ជម្ងឺអស់សង្ឃឹម ការស្អប់ខ្ពើម និងអំពើអាក្រក់ទាំងអស់ដែលបានចូលមកក្នុងពិភពលោករបស់យើង។

នេះស្តាប់ទៅដូចជាចុងបញ្ចប់ដ៏ក្រៀមក្រំបំផុតអញ្ចឹង ប៉ុន្តែ នេះមិនមែនជាចុងបញ្ចប់នៃរឿងនៅឡើយទេ ។ ព្រះទ្រង់ស្រឡាញ់មនុស្សលោកខ្លាំងណាស់ ដែលទ្រង់បានសន្យាថា នឹងមាននរណាម្នាក់មកសង្គ្រោះយើង ។
តើបុគ្គលនោះជានរណា? នោះគឺជាអង្គទ្រង់ផ្ទាល់ដែលបានយាងចុះមកលើផែនដីរបស់យើង។ ជាព្រះដែលមានរាងដូចមនុស្សលោក ទ្រង់មានព្រះនាមថា (យេស៊ូវ)។ ព្រះយេស៊ូវទ្រង់បានប្រសូតជាមនុស្ស ហើយរស់នៅដូចមនុស្ស ដូចយើងដែរ ប៉ុន្តែមិនដូចយើងទេ គឺទ្រង់គ្មានបាបទេ ទ្រង់បានធ្វើការអស្ចារ្យជាច្រើន ទ្រង់បានព្យាបាលមនុស្សឈឺ បានប្រោសមនុស្សស្លាប់ឲ្យរស់ឡើងវិញ ហើយបានធ្វើការអស្ចារ្យជាច្រើនទៀត ដែលបង្ហាញថាទ្រង់ជាព្រះ។ ចេញពីសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់ ព្រះយេស៊ូវទ្រង់បានយាងមក ហើយសុគតនៅលើឈើឆ្កាង ពីព្រោះវាជាមធ្យោបាយតែមួយគត់ ដើម្បីដកអំពើបាប និងទណ្ឌកម្មរបស់ពួកយើងបាន។ នៅពេលតែមួយផងដែរ ទ្រង់បានឈ្នះអំពើបាប និងការស្លាប់ដោយការរស់ពីស្លាប់ឡើងវិញ របស់ព្រះអង្គ ។ ឥឡូវនេះ នៅពេលដែលយើងសារភាពអំពើបាបយើងទាំងអស់ហើយ សូមព្រះអង្គអត់ទោសនិងសម្អាតអំពើបាប រួចព្រះយេស៊ូវទ្រង់នឹងយាងចូលមករស់នៅក្នុងចិត្តរបស់យើង។ បន្ទាប់មកយើងអាចមានទំនាក់ទំនងជាមួយព្រះម្តងទៀតបាន មិនមែនតែនៅលើផែនដីនេះទេ តែជារៀងរហូត ។

**១ កូរិនថូស ១៥: ២២** ព្រោះ ដូចជាគ្រប់មនុស្សទាំងអស់បានត្រូវស្លាប់ ក្នុងលោកអ័ដាមជាយ៉ាងណា នោះគ្រប់គ្នាក៏នឹងបានប្រោសឲ្យរស់ ក្នុងព្រះគ្រីស្ទយ៉ាងនោះដែរ។

**1.02 ការធ្លាក់ចុះសេចក្តីណែនាំ-សម្រាប់គ្រូបង្រៀន កំណត់សំគាល់**

១. គ្រប់របស់ទាំងអស់គឺល្អឥតខ្ចោះ នៅពេលព្រះទ្រង់បានបង្កើតផែនដីមក គឺគ្មានអំពើរបាបទេ។ គ្មានការមិនស្តាប់បង្គាប់។ ព្រះបានប្រទានសួនច្បារដ៏ស្រស់ស្អាតមួយឲ្យអ័ដាម និងអេវ៉ាសម្រាប់រស់នៅ ។ យ៉ាងណាក៏ដោយ គឺមានបញ្ញត្តិយ៉ាងសំខាន់មួយ មិនត្រូវបរិភោគផ្លែឈើដឹងខុសត្រូវ ល្អ និងអាក្រក់ ដែលព្រះទ្រង់បានប្រាប់ដល់ពួកគេ។

២. អារក្សសាតាំង វាគឺជាខ្មាំងសត្រូវរបស់ព្រះអម្ចាស់ ។ វាបានក្លែងខ្លួនជាសត្វពស់ ហើយនិយាយប្រាប់អេវ៉ាថាមិនអីទេក្នុងការដែលបរិភោគផ្លែដឹងខុសត្រូវនោះ ។ នាងបានបរិភោគវា ហើយឲ្យខ្លះទៅប្តីរបស់នាង គឺលោកអ័ដាម ។

៣. ព្រះទ្រង់ព្រួយព្រះទ័យខ្លាំងណាស់។ ទ្រង់បានដឹងថាអ័ដាម និងអេវ៉ាបានស្តាប់តាមសម្តីអារក្សសាតាំង។ ឥឡូវពួកគេត្រូវបានដាច់ចេញពីព្រះដោយសារបាបរបស់គេ ។ ដោយហេតុនេះហើយ សេចក្តីអាក្រក់ទាំងឡាយបានចូលមកលើផែនដីនេះ ។

៤. គឺមានតែវិធីម្យ៉ាងប៉ុណ្ណោះ ដើម្បីដោះស្រាយស្ថានភាពដ៏អាក្រក់នេះបាន។ ព្រះនឹងបញ្ជូននរណាម្នាក់ដើម្បីសង្គ្រោះមនុស្សលោកពីអំពើរបាបរបស់ពួកគេ។ ព្រះទ្រង់បានយាងមកលើផែនដីនេះ ជាមនុស្សម្នាក់ គឺព្រះនាម(ព្រះយេស៊ូវ)។ ព្រះយេស៊ូវនឹងត្រូវសុគតដើម្បីលោះយកបាបរបស់គេចេញ ។

៥. នៅពេលយើងទទួលជឿលើព្រះយេស៊ូវ យើងអាចទូលសូមព្រះអង្គឲ្យទ្រង់អត់ទោសបាបដល់យើងបាន។ ហើយយើងនឹងអាចនៅជាប់ជាមួយព្រះអង្គម្តងទៀត ។

**សំណួរ**

១. តើច្បាប់បញ្ញត្តិអ្វី ដែលព្រះប្រទានឲ្យអ័ដាមនិងអេវ៉ា?
២. តើនរណាជាខ្មាំងសត្រូវរបស់ព្រះ?
៣. តើអារក្សសាតាំងបានប្រាប់អ្វីខ្លះ ដល់អេវ៉ា?
៤. តើមានអ្វីកើតឡើងនៅពេលអ័ដាម និងអេវ៉ាបានបរិភោគផ្លែដឹងខុសត្រូវ?
៥. តើព្រះបានបញ្ជូនអ្នកណាមក ដើម្បីសង្គ្រោះមនុស្សលោកឲ្យរួចពីបាប?
៦. តើមានអ្វីកើតឡើងនៅពេលយើងជឿលើព្រះយេស៊ូវ ហើយសុំឲ្យទ្រង់អត់ទោសបាបឲ្យយើង?

**ចម្លើយ**

១. ព្រះបានប្រាប់អ័ដាមនិងអេវ៉ាថា មិនត្រូវបរិភោគផ្លែឈើដឹងខុសត្រូវឡើយ ។
២. អារក្សសាតាំងគឺជាខ្មាំងសត្រូវរបស់ព្រះអម្ចាស់ ។
៣. អារក្សសាតាំងបានប្រាប់អេវ៉ាថា វាមិនអីទេក្នុងការដែលបរិភោគផ្លែឈើនោះ ។
៤. នៅពេលអ័ដាមនិងអេវ៉ាមិនស្តាប់បង្គាប់ព្រះ ហើយបានបរិភោគផ្លែឈើនោះ ពួកគេបានដាច់ចេញពីព្រះអម្ចាស់។
៥. ព្រះអម្ចាស់បានបញ្ជូនព្រះយេស៊ូវមក ដើម្បីសង្គ្រោះពួកយើង។
៦. នៅពេលព្រះយេស៊ូវអត់ទោសបាបឲ្យយើងហើយ នោះយើងអាចនៅជាប់នឹងព្រះអង្គម្តងទៀតបាន



www.kidsofdestiny.org